បង្អស់ រួចយើងរាល់គ្នាដែលកំពុងតែរស់នៅ ក៏នឹងបានលើកឡើង ទៅក្នុងពពកជាមួយគ្នាទាំងអស់ ដើម្បីឲ្យបានជួបជុំនឹងព្រះអម្ចាស់នៅនាអាកាស យ៉ាងនោះ យើងនឹងនៅជាមួយនឹងព្រះអម្ចាស់ជាដរាបទៅ ដូច្នេះ ចូរកំសាន្តចិត្តគ្នាទៅវិញទៅមក ដោយដំណើរនេះចុះ។ (១ថែស្សាឡូនិច 4:13–18)

យើងត្រូវចងចាំថា ព្រះបន្ទូលទាំងនេះត្រូវបានប្រទានមក ដើម្បីជាការលើកទឹកចិត្តនិងការកម្សាន្តចិត្តសម្រាប់យើង។

យើងនឹងបានផ្លាស់ប្រែ

ព្រឹត្តិការណ៍ដដែលនេះ ត្រូវបានសាវ័កប៉ុលពិពណ៌នាម្តងទៀតនៅក្នុងកណ្ឌគម្ពីរ ១ កូរិនថូស៖

នែ ខ្ញុំប្រាប់អ្នករាល់គ្នាពីសេចក្តីអាថ៌កំបាំង គឺថាយើងទាំងអស់គ្នានឹងមិនដេកលក់ទៅទេ តែទាំងអស់គ្នានឹងបានផ្លាស់ប្រែទៅក្នុង១រំពេចវិញ គឺក្នុង១ប៉ព្រិចភ្នែកប៉ុណ្ណោះ ក្នុងកាលដែលឮសូរត្រែក្រោយបង្អស់ ដ្បិតត្រែនឹងឮឡើងមែន នោះពួកស្លាប់នឹងរស់ឡើងវិញ មិនពុករលួយទៀតឡើយ រួចយើងរាល់គ្នានឹងបានផ្លាស់ប្រែទៅ។ (១កូរិនថូស 15:51–52)

ពាក្យ «ដេកលក់» នៅក្នុងបទគម្ពីរទាំងនេះ ត្រូវបានប្រើសម្រាប់តែអ្នកដែលស្លាប់នៅក្នុងជំនឿប៉ុណ្ណោះ ពីព្រោះវាបង្ហាញពីការភ្ញាក់ឡើងវិញ។ តើនោះនឹងក្លាយជាព្រឹត្តិការណ៍ដ៏អស្ចារ្យប៉ុណ្ណា!

ខ្ញុំចូលចិត្តពាក្យថា "ក្នុង១ប៉ព្រិចភ្នែក" ខ្លាំងណាស់។ វាមានន័យថា នៅគ្រាមួយ អ្នក និងខ្ញុំ ក្នុងនាមជាអ្នកជឿអាចកំពុងសម្លឹងមើលគ្នាទៅវិញទៅមក។ បន្ទាប់មក នឹងមានពន្លឺដ៏ចែងចាំងមួយភ្លឺឡើង ដែលធ្វើឲ្យយើងព្រិចភ្នែកមួយរំពេច។ នៅពេលយើងបើកភ្នែកឡើងវិញ យើងនឹងឃើញគ្នាទៅវិញទៅមក ក្នុងសភាពថ្មីទាំងស្រុង។ ក្នុងមួយរំពេចនោះ រូបកាយខាងសាច់ឈាមរបស់យើងនឹងត្រូវបានផ្លាស់ប្រែទាំងស្រុង ដោយព្រះចេស្តា ដ៏អស្ចារ្យរបស់ព្រះ។ នោះហើយជាក្តីសង្ឃឹមដ៏រុងរឿង ដែលកំពុងរង់ចាំអ្នកជឿពិតប្រាកដគ្រប់រូបនៅខាងមុខ។

យើងនឹងបានដូចជាទ្រង់

ពួកស្ងួនភ្ងាអើយ ឥឡូវនេះយើងរាល់គ្នាជាកូនព្រះហើយ តែដែលយើងរាល់គ្នានឹងបានទៅជាយ៉ាងណាទៀត នោះមិនទាន់សំដែងមកនៅឡើយ ប៉ុន្តែ យើងដឹងថា កាលណាទ្រង់លេចមក នោះយើងនឹងបានដូចជាទ្រង់ ដ្បិតដែលទ្រង់យ៉ាងណា នោះយើងនឹងឃើញទ្រង់យ៉ាងនោះឯង។ (១យ៉ូហាន 3:2)

យើងគឺជាកូនរបស់ព្រះជាម្ចាស់រួចហើយ តាមរយៈជីវិតខាងក្នុងដែលយើងមាន៖

...ព្រះគ្រីស្ទទ្រង់សណ្ឋិតនៅក្នុងអ្នករាល់គ្នា ដែលជាទីសង្ឃឹមយ៉ាងឧត្តម។ (កូល៉ុស 1:27)

ប៉ុន្តែការសម្តែងពេញលេញនៃជីវិតនោះ នៅក្នុងរូបកាយខាងក្រៅរបស់យើង នឹងកើតឡើងតែនៅពេលដែលព្រះយេស៊ូវយាងមក ក្នុងសិរីល្អរបស់ទ្រង់ប៉ុណ្ណោះ។ នៅពេលនោះ យើងនឹងបានដូចជាទ្រង់។ យើងនឹងទទួលបានរូបកាយ ដូចជារូបកាយរបស់ទ្រង់ ដ្បិតដែលទ្រង់យ៉ាងណា នោះយើងនឹងឃើញទ្រង់យ៉ាងនោះឯង។

នឹងមានការបើកសម្តែងអំពីព្រះគ្រីស្ទ ដែលបានរស់ឡើងវិញពេញដោយសិរីល្អ និងត្រូវបានលើកតម្កើងដល់ពួកអ្នកជឿដែលកំពុងរង់ចាំទ្រង់ ហើយនឹងមានអំណាចផ្លាស់ប្រែយ៉ាងអស្ចារ្យ។ ការបើកសម្តែងនោះនឹងផ្លាស់ប្រែរូបកាយដែលរមែងស្លាប់របស់យើង ឲ្យទៅជារូបកាយមិនចេះស្លាប់ រូបកាយទន់ខ្សោយរបស់យើង ឲ្យទៅជារូបកាយដ៏មានកម្លាំង រូបកាយដែលគួរឲ្យអាម៉ាស់របស់យើង ឲ្យទៅជារូបកាយប្រកបដោយសិរីល្អ និងរូបកាយដែលពុករលួយរបស់យើង ឲ្យទៅជារូបកាយមិនចេះពុករលួយវិញ។ លោកប៉ុល បាននិយាយនៅក្នុង ភីលីព 3:21 ថា៖ *"...តាមដែលព្រះចេស្តាទ្រង់ពូកែនឹងបញ្ចុះបញ្ចូលគ្រប់ទាំងអស់ នៅក្រោមអំណាចទ្រង់ផង។"*

តើលោកអ្នកជឿការនេះឬទេ? ប្រសិនបើយើងរក្សា ព្រះបន្ទូលដ៏អស្ចារ្យទាំងនេះ ទុកនៅក្នុងចិត្ត នោះវានឹងបន្លើកទឹកចិត្ត និងជំរុញចិត្តយើងជានិច្ច ក្នុងការប្រឈមមុខនឹងសេចក្តីស្លាប់ដោយជ័យជម្នះ។

ស្វែងយល់ពីព្រះបន្ទូលព្រះឲ្យកាន់តែស៊ីជម្រៅ

សេចក្តីបង្រៀននេះផ្អែកលើកូនសៀវភៅ «សេចក្តីសង្ឃឹមលើសពីទុក្ខសោក»។ លោក ដេរិក ព្រីនស៍ លើកឡើងអំពីប្រធានបទមួយចំនួនដែលពិបាកប្រឈមមុខ សូម្បីតែសម្រាប់អ្នកដែលរស់នៅក្នុងសេចក្តីសង្ឃឹមនៃព្រះយេស៊ូវគ្រីស្ទក៏ដោយ។ លោកអ្នកអាចទាញយកដោយឥតគិតថ្លៃពី គេហទំព័ររបស់យើង

www.derekprince.com/km-kh/resources

ស្កេន QR ដើម្បីចូលគេហទំព័រ DPM-KH

ព័ន្ធកិច្ច ដេរេក ព្រីនស៍ កម្ពុជា

Facebook / Youtube: Derek Prince Ministries Cambodia | www.derekprince.com/km-kh

ISSUE #099

លោក ដេរេក ព្រីនស៍៖ សេចក្តីបង្រៀនជាលិខិត

ការយល់ដឹងពីព្រះគម្ពីរ ដើម្បីផ្លាស់ប្រែជីវិតរបស់អ្នក

Free COPY



ជ័យជំនះនៃការរស់ឡើងវិញ

នៅពេលដែលយើងឈានចូលដល់រដូវបុណ្យអ៊ីស្ទើរ ចិត្ត និងគំនិតរបស់យើងត្រូវបាននាំឲ្យផ្តោតទៅលើជ័យជម្នះដ៏ធំបំផុតក្នុងប្រវត្តិសាស្ត្រមនុស្សជាតិទាំងមូល គឺការរស់ឡើងវិញរបស់ព្រះយេស៊ូវគ្រីស្ទ។ សំបុត្រដែលជាកេរដំណែលនៃការបង្រៀននេះ ត្រូវបានកែសម្រួលចេញពីកូនសៀវភៅរបស់លោក ដេរេក ព្រីនស៍ ដែលមានចំណងជើងថា "សេចក្តីសង្ឃឹមលើសពីទុក្ខព្រួយ"។

ខ្ញុំបានសរសេរសេចក្តីទាំងនេះ ផ្ញើមកអ្នករាល់គ្នា ដែលជឿដល់ព្រះនាមព្រះរាជបុត្រានៃព្រះ ដើម្បីឲ្យអ្នករាល់គ្នាបានដឹងថា អ្នករាល់គ្នាមានជីវិតអស់កល្បជានិច្ចហើយ

១ យ៉ូហាន 5:13

ការរស់ឡើងវិញរបស់ព្រះគ្រីស្ទ ជានាដល់យើងនូវជ័យជម្នះលើសត្រូវទាំងអស់របស់យើងជាពិសេសលើសេចក្តីស្លាប់។ សាសនាណាមួយ ដែលមិនមានចម្លើយដ៏គ្រប់គ្រាន់ ចំពោះបញ្ហាសេចក្តីស្លាប់នោះមិនអាចបំពេញតម្រូវការដ៏ជ្រាលជ្រៅបំផុតរបស់មនុស្សជាតិបានឡើយ។ ខ្ញុំជឿថា គ្រីស្ទានគឺជាសាសនាតែមួយគត់ ដែលមានចម្លើយសម្រាប់បញ្ហានេះ។ ហើយចម្លើយនោះបានមកតាមរយៈការសុគត និងការរស់ឡើងវិញរបស់ព្រះយេស៊ូវ។

ព្រះគ្រីស្ទមានជ័យជម្នះដោយការរស់ឡើងវិញ

រូបភាពដ៏រុងរឿងមួយនៃព្រះគ្រីស្ទ ក្នុងនាមជាព្រះអង្គដែលបានមានជ័យជម្នះដោយការរស់ឡើងវិញ ត្រូវបានកត់ត្រាទុកនៅក្នុងកណ្ឌគម្ពីរវិវរណៈ។ នេះគឺជារបៀបដែលព្រះយេស៊ូវបានបង្ហាញអង្គទ្រង់ដល់សាវ័កយ៉ូហាន នៅលើកោះប៉ាតម៉ុស៖

ហើយនៅថ្ងៃនៃព្រះអម្ចាស់ ខ្ញុំបានត្រឡប់ជានៅដោយវិញ្ញាណ នោះក៏ឮសំឡេងបន្លឺឡើង ដូចជាសូរត្រែ នៅខាងក្រោយខ្ញុំថា... អញគឺជា អាលផា និងជាអូមេកា គឺជាដើម ហើយជាចុង ខ្ញុំក៏បែរខ្លួនទៅមើលសំឡេង ដែលមានបន្ទូលមកខ្ញុំនោះ លុះបែរខ្លួនទៅហើយ នោះក៏ឃើញជើងចង្កៀងមាស ៧ នៅត្រង់កណ្តាលជើងចង្កៀងទាំង៧នោះ ឃើញមាន១អង្គ ដូចជាកូនមនុស្ស... ហើយព្រះភក្ត្រទ្រង់ ដូចជាថ្ងៃភ្លឺពេញអំណាច កាលខ្ញុំឃើញទ្រង់ នោះខ្ញុំដួលនៅទៀបព្រះបាទាទ្រង់ដូចជាស្លាប់ តែទ្រង់ដាក់ព្រះហស្តស្តាំលើខ្ញុំ ដោយបន្ទូល

ថា កុំខ្លាចអ្វីឡើយ អញជាដើម ហើយជាចុង ជាព្រះដ៏រស់នៅ អញបានស្លាប់ តែមើល អញរស់នៅអស់កល្បជានិច្ចរៀងរាបតទៅវិញ អញក៏មានកូនសោនៃសេចក្ដីស្លាប់ នឹងស្ថានឃុំព្រលឹងមនុស្សស្លាប់ដែរ។

(វិវរណៈ 1:10–11ក, 12–13ក, 16ខ–18)

ខគម្ពីរនេះ គឺជាការពិពណ៌នាអំពីព្រះគ្រីស្ទដែលបានរស់ឡើងវិញ៖ *"ព្រះបាទាទ្រង់ដូចជាលង្ហិនរលើងដែលភ្លឺផ្លេកៗ... ព្រះសូរសៀងទ្រង់ដូចជាសូរនៃទឹកច្រើន... ព្រះសិរសា នឹងព្រះកេសាទ្រង់សដូចជារោមចៀមដែលស ... ព្រះនេត្រទ្រង់ដូចជាអណ្តាតភ្លើង... ក៏មានដាវមុខ២ដ៏មុត ចេញពីព្រះឱស្ឋទ្រង់មក។"* អ្វីដែលគួរឲ្យកត់សម្គាល់នោះគឺ មុនពេលព្រះយេស៊ូវរស់ឡើងវិញ សាវ័កយ៉ូហានធ្លាប់ផ្អែកក្បាលរបស់គាត់លើព្រះឱរារបស់ព្រះយេស៊ូវផ្ទាល់។ គាត់មានទំនាក់ទំនងដ៏ជិតស្និទ្ធ និងមានអារម្មណ៍សុខស្រួលជាមួយទ្រង់យ៉ាងខ្លាំង។ ប៉ុន្តែ នៅពេលគាត់បានជួបព្រះគ្រីស្ទដែលបានរស់ឡើងវិញ និងត្រូវបានលើកតម្កើងក្នុងសិរីល្អ គាត់ត្រូវបានព្រះចេស្តា និងសិរីល្អរបស់ទ្រង់គ្របដណ្តប់ទាំងស្រុង។ សាវ័កយ៉ូហាន ខ្លួនឯងបាននិយាយថា៖ *"ខ្ញុំភ្លាយដូចជាមនុស្សស្លាប់ម្នាក់"* ។ ការនេះបង្ហាញឲ្យឃើញពីទំហំដ៏អស្ចារ្យនៃព្រះចេស្តា និងសិរីល្អ ដែលត្រូវបានសម្តែងឡើងនៅក្នុងព្រះគ្រីស្ទ ដែលបានរស់ឡើងវិញ។

ជ័យជំនះលើសេចក្តីស្លាប់

តាមរយៈការសិក្សារបស់យើងថា យើងបានដឹងថា តាមរយៈការរស់ឡើងវិញរបស់ព្រះយេស៊ូវ សេចក្តីស្លាប់ត្រូវបានបរាជ័យ។ ព្រះយេស៊ូវបានដកអំណាច និងទ្រនិចនៃសេចក្តីស្លាប់ចេញ។

ដ្បិតត្រូវតែរូបកាយដ៏ពុករលួយនេះ បានប្រដាប់ដោយសេចក្ដីមិនពុករលួយវិញ ហើយរូបកាយដែលរមែងស្លាប់នេះ ត្រូវតែបានប្រដាប់ដោយសេចក្ដីមិនចេះស្លាប់វិញដែរ កាលណារូបកាយពុករលួយនេះ បានប្រដាប់ដោយសេចក្ដីមិនពុករលួយ ហើយរូបកាយដែលតែងតែស្លាប់នេះ បានប្រដាប់ដោយសេចក្ដីមិនចេះស្លាប់វិញ នោះទើបនឹងបានសំរេចតាមពាក្យ ដែលចែងទុកមកថា «សេចក្ដីជ័យជំនះបានលេបសេចក្ដីស្លាប់បាត់ហើយ» ជ័យជម្នះរបស់ព្រះគ្រីស្ទបានលេបត្របាក់សេចក្តីស្លាប់។ «ឱសេចក្ដីស្លាប់អើយ ទ្រនិចឯងនៅឯណា សេចក្ដីស្លាប់អើយ ជ័យជំនះរបស់ឯងនៅឯណា» រីឯទ្រនិចនៃសេចក្ដីស្លាប់ គឺជាអំពើបាប ហើយអំណាចរបស់បាប គឺជាក្រិត្យវិន័យ តែអរព្រះគុណដល់ព្រះអង្គ ពីព្រោះទ្រង់ប្រទានឲ្យយើងរាល់គ្នាមានជ័យជំនះ ដោយសារព្រះយេស៊ូវគ្រីស្ទ ជាព្រះអម្ចាស់នៃយើង។

(១កូរិនថូស 15:53–57)

ព្រះយេស៊ូវ បានដកទ្រនិចនៃសេចក្តីស្លាប់ចេញ។ ឥឡូវនេះ សេចក្តីស្លាប់បានក្លាយជាអ្នកបម្រើសម្រាប់គោលបំណងរបស់ព្រះ វាជាសត្រូវដែលត្រូវបានយកឈ្នះរួចហើយ ហើយកំពុងរង់ចាំថ្ងៃដែលវានឹងត្រូវបំផ្លាញចោលទាំងស្រុង។

ពីសេចក្តីស្លាប់ទៅកាន់ជីវិត

ដោយសារជ័យជម្នះរបស់ព្រះគ្រីស្ទលើសេចក្តីស្លាប់ ខ្ញុំចង់បង្ហាញអំពីព្រះបន្ទូលសន្យាមួយចំនួន ដែលព្រះយេស៊ូវបានមានបន្ទូលទុកជាមុន ដោយទន្ទឹងរង់ចាំជ័យជម្នះរបស់ទ្រង់។ នៅពេលទ្រង់ប្រើឃ្លាថា «ប្រាកដមែន» នោះមានន័យថា ព្រះបន្ទូលដែលទ្រង់នឹងមានបន្ទូលបន្ទាប់ គឺមានសិទ្ធិអំណាច និងអាចទុកចិត្តបានទាំងស្រុង។

ប្រាកដមែន ខ្ញុំប្រាប់អ្នករាល់គ្នាជាប្រាកដថា អ្នកណាដែលស្តាប់ពាក្យខ្ញុំ ហើយជឿដល់ព្រះអង្គដែលចាត់ឲ្យខ្ញុំមក អ្នកនោះមានជីវិតដ៏នៅអស់កល្បជានិច្ច ហើយមិនដែលត្រូវជំនុំជំរះឡើយ គឺបានកន្លងហួសពីសេចក្តីស្លាប់ ទៅដល់ជីវិតវិញ។

(យ៉ូហាន 5:24)

សូមកត់សម្គាល់ថា សេចក្តីពិតនេះត្រូវបានបញ្ជាក់ថា ជាអ្វីដែលបានកើតឡើងរួចហើយ។ វាមិនមែនជាអ្វីដែលនឹងកើតឡើងនៅពេលអនាគតទេ។ តាមរយៈជំនឿរបស់យើងលើការសុគត និងការរស់ឡើងវិញរបស់ព្រះយេស៊ូវគ្រីស្ទ យើងបានឆ្លងផុតពីសេចក្តីស្លាប់ទៅកាន់ជីវិតរួចហើយ។ សេចក្តីស្លាប់មិនមានអំណាចលើយើងទៀតទេ ហើយក៏លែងមានសិទ្ធិទាមទារអ្វីពីយើងទៀតដែរ។ សេចក្តីស្លាប់គ្រាន់តែជាទ្វារចូលទៅកាន់ជីវិតថ្មីមួយប៉ុណ្ណោះ។ នៅក្នុង យ៉ូហាន 8:51–52 យើងបានទទួលសេចក្តីសន្យានេះពីព្រះយេស៊ូវផ្ទាល់៖ *"ប្រាកដមែន ខ្ញុំប្រាប់អ្នករាល់គ្នាជាប្រាកដថា បើអ្នកណាកាន់តាមពាក្យខ្ញុំ អ្នកនោះមិនត្រូវឃើញសេចក្តីស្លាប់... បើអ្នកណាកាន់តាមពាក្យខ្ញុំ នោះមិនដែលភ្លក់សេចក្តីស្លាប់ នៅអស់កល្បរៀងទៅវិញ"* ។

តើអ្នកអាចជឿសេចក្តីពិតនេះ សម្រាប់ខ្លួនអ្នក និងសម្រាប់មនុស្សជាទីស្រឡាញ់របស់អ្នកបានទេ? នេះគឺជាព្រះបន្ទូលសន្យាដែលចេញពីព្រះឱស្ឋរបស់ព្រះយេស៊ូវផ្ទាល់។ ទ្រង់មិនបានមានបន្ទូលថា យើងនឹងមិនជួបប្រទះការស្លាប់ខាងរូបកាយឡើយ។ ប៉ុន្តែ ទ្រង់បានមានបន្ទូលថា សេចក្តីស្លាប់និងស្ថានមនុស្សស្លាប់ លែងមានសិទ្ធិអំណាចលើយើងទៀតហើយ។ ការគ្រប់គ្រងដែលពួកវាធ្លាប់មានលើយើង ត្រូវបានលុបបំបាត់ដោយព្រះនាម និងព្រះលោហិតរបស់ព្រះយេស៊ូវ។ នៅពេលយើងប្រឈមមុខនឹងសេចក្តីស្លាប់ យើងមិនកំពុងធ្លាក់ចុះទៅក្នុងនគរនៃសេចក្តីងងឹតឡើយ។ ផ្ទុយទៅវិញ យើងកំពុងចូលទៅក្នុងព្រះវត្តមានរបស់ព្រះ។ នេះគឺជាការធានាដែលយើងមាន តាមរយៈជំនឿលើព្រះយេស៊ូវ ។

ការរស់ឡើងវិញនៃមនុស្សសុចរិត

ជាផ្នែកមួយដ៏សំខាន់នៃការយាមមកវិញរបស់ព្រះយេស៊ូវ ការរស់ឡើងវិញនៃមនុស្សសុចរិតដែលជាអ្នកជឿនឹងកើតឡើង។ ដោយទទួលការបើកសម្តែងពីព្រះ នេះគឺជារបៀបដែលសាវ័កប៉ុលបានពិពណ៌នាអំពីព្រឹត្តិការណ៍នោះ៖

បងប្អូនអើយ ខ្ញុំមិនចង់ឲ្យអ្នករាល់គ្នាឥតដឹង ពីពួកអ្នកដែលដេកលក់ទៅហើយទេ ក្រែងអ្នករាល់គ្នាកើតទុក្ខព្រួយដូចជាអ្នកឯទៀត ដែលគ្មានសង្ឃឹម ដ្បិតបើយើងជឿថា ព្រះយេស៊ូវបានសុគត ព្រមទាំងរស់ឡើងវិញហើយ នោះត្រូវជឿថា ព្រះទ្រង់នឹងនាំអស់អ្នក ដែលដេកលក់ទៅក្នុងព្រះយេស៊ូវ ឲ្យបានមកជាមួយនឹងទ្រង់ដែរ នោះគឺ អ្នកដែលបានស្លាប់ក្នុងជំនឿ ដ្បិតយើងខ្ញុំប្រាប់មកអ្នករាល់គ្នាតាមព្រះបន្ទូលនៃព្រះអម្ចាស់ដូច្នេះថា យើងដែលរស់នៅជាប់ ដរាបដល់ព្រះអម្ចាស់យាងមក នោះយើងមិនទៅមុនពួកអ្នក ដែលបានដេកលក់ទៅហើយនោះទេ ព្រោះព្រះអម្ចាស់ទ្រង់នឹងយាងចុះពីស្ថានសួគ៌មក ដោយស្រែកបង្គាប់ ១ព្រះឱស្ឋ ទាំងមានឮសំឡេងមហាទេវតា នឹងត្រែរបស់ព្រះផង នោះពួកស្លាប់ក្នុងព្រះគ្រីស្ទនឹងរស់ឡើងវិញជាមុន

